ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល តាងនាមប្រជារាស្ត្រខ្មែរ

សំណុំរឿង ព្រហ្មទណ្ឌ តុលាការកំពូល

លេខ ៖ ៣៩

ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០២

សាលដីកាលេខ ៖ ៥០

ចុះថ្ងៃទី១៧ខែធ្នូ២០០៣

បានបើកសវនាការជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០០៣ដោយមានសមាសភាពដូចទៅ៖

១ - ឯកឧត្តម ... ជាប្រធាន

២ - លោក ... ជាចៅក្រម

៣ - លោក ... ជាចៅក្រមរបាយការណ៍

៤ - លោក ... ជាចៅក្រម

៥ - លោក ... ជាចៅក្រម

លោក ...ជាក្រឡាបញ្ជី

**តំណាងមហាអយ្យការ**

ឯកឧត្តម ...អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ០១”គ” ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ ៣៩ ចុះថ្ងៃទី០៨ ខែមកក្កដា ឆ្នាំ២០០២ របស់តុលាការកំពូល។

**ពីបទ**៖ មនុស្សឃាតដោយចេតនាគិតទុកជាមុនប្រព្រឹត្តនៅភូមិព្រៃពង្រ ឃុំពញាពន់ ស្រុកពញាឮ ខេត្តកណ្ដាល កាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៣១ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០.៩.១៩៩២ ។

១ - ជនជាប់ចោទឈ្មោះ **ផ** (ជាម្ចាស់បណ្ដឹងសាទុក្ខ) ភេទប្រុសអាយុ33 ឆ្នាំ ជាតិខ្មែរ កើតនៅ ឃុំសំរោង ស្រុកពញាឮ ខេត្តកណ្ដាល របររកស៊ីធ្វើប៉ូលីស ទីលំនៅសព្វថ្ងៃចាប់ខ្លួននៅភូមិត្រពាំងព្រីង ឃុំពញាពន់ ស្រុកពញាឮ ខេត្តកណ្ដាល ឪពុកឈ្មោះ...ម្ដាយឈ្មោះ...ប្រពន្ធឈ្មោះ...មានកូន២នាក់។ ក្នុងឃុំ។

២ - ជនជាប់ចោទឈ្មោះ **ទស** (ជាចុងបណ្ដឹងសាទុក្ខ) ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ កើតនៅភូមិធំ ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្ដាល ឪពុកឈ្មោះ...ម្ដាយឈ្មោះ...ប្រពន្ធឈ្មោះ...កូនគ្មាន។ ក្រៅឃុំ។

- មេធាវីលោក...

៣ - ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ **បភ** ភេទស្រី អាយុ៥២ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ ភូមិព្រៃពង្រ ឃុំពញាពន់ ស្រុកពញាឮ ខេត្តកណ្ដាល។

៤ - ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ (ជាម្ចាស់បណ្ដឹងសាទុក្ខ)

- តាមពាក្យបណ្ដឹងចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៨ របស់ឈ្មោះ **បភ** ប្ដឹងពីឈ្មោះ **ផផ** ដែលបានបាញ់សម្លាប់ប្ដីរបស់ខ្លួន កាលពីថ្ងៃទី ១៩.១២.៩៨ វេលាម៉ោង១៩ និង៣០នាទីយប់ឈ្មោះ **ផផ** បានមកឈរហៅប្ដីរបស់ខ្លួននៅមុខផ្ទះចំងាយប្រហែល៦ម៉ែត្រ ពេលនោះប្ដីខ្លួនចេញមកដោយមានកូនរបស់ខ្លួនឈ្មោះ **តភ** មើលពីក្នុងផ្ទះមកដែរ ជួនពេលនោះ កូនខ្លួនបានលឺសូរគ្រាប់

កាំភ្លើងចំនួន៦គ្រាប់ ប្ដីខ្លួនក៏ដួលហើយកូនក៏ស្រែកឱ្យគេជួយព្រោះគេលបបាញ់ឪពុកខ្លួន ខណៈនោះពួកកូនខ្លួនដែលមានឈ្មោះ **តត, តភ, ហហ និងតវ** បានរត់មកស្ដាប់ឪពុកខ្លួនផ្ដាំថា "ឈ្មោះ **ផផ** ហៅគាត់ចេញពីផ្ទះហើយបាញ់តែម្ដង។

- បានឃើញដីកាលើកលែងចោទប្រកាន់លេខ ១៧ ដ.ក.ល.ច ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០០០ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តកណ្ដាលដែលបានសម្រេច៖

១ - លើកលែងចោទលើឈ្មោះ **ទស** ភេទប្រុស អាយុ៣៥ឆ្នាំ ពីបទមនុស្សឃាតដោយចេតនាគិតទុកជាមុន។

២- លើកលែងចោទលើឈ្មោះ **បវ** ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ ពីបទមនុស្សឃាតដោយចេតនាគិតទុកជាមុន។

-បានឃើញដីកាលើកលែងចោទលេខ៧២ ដ.ក.ល.ច ចុះថ្ងៃទី ២០.១០.២០០០ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តកណ្ដាល ដែលបានសម្រេច៖

-លើកលែងចោទប្រកាន់លើឈ្មោះ **ផផ** ភេទប្រុស អាយុ៣៣ឆ្នាំ ជាតិខ្មែរ ពីបទមនុស្សឃាតដោយចេតនាគិតទុកជាមុន។

- បានឃើញបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ របស់ឈ្មោះ **បភ** ប្ដឹងមិនសុខចិត្តពីដីកាលើកលែងចោទប្រកាន់លេខ១៧ ដ.ក.ល.ច ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០០០ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តកណ្ដាលត្រង់ចំណុចដីកាទាំងមូល។

- បានឃើញបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០ របស់តំណាងអយ្យការ អមតុលាការខេត្តកណ្ដាល ប្ដឹងមិនសុខចិត្តពីដីកាលើកលែង

ចោទប្រកាន់លេខ៧២ ដ.ក.ល.ច ចុះថ្ងៃទី ២០ ខែតុលា ឆ្នាំ២០០០ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តកណ្តាលលើដីកាទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថាៈ សុំបដិសេធដីកាលើកលែងចោទប្រកាន់លេខ៧២ ដ.ក.ល.ច ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០០០ របស់តុលាការខេត្តកណ្តាល និងសុំឱ្យចោទប្រកាន់លើឈ្មោះ **ផផ** និងឈ្មោះ **ទស** វិញ។

បានឃើញសាលដីកាព្រហ្មទណ្ឌលេខ០១"គ" ចុះថ្ងៃទី ០២ ខែមករា ឆ្នាំ ២០០២ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចៈ

១- ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ២០០០ របស់លោកព្រះរាជអាជ្ញាអមតុលាការខេត្តកណ្តាល និងបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ របស់ឈ្មោះ **បភ** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែលើកចោលដោយទាស់នឹងគតិច្បាប់។

២-តម្កល់ដីកាលើកលែងចោទប្រកាន់ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តកណ្តាលលេខ៧២ ដ.ក.ល.ច ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០០ ដែលប្តឹងឧទ្ធរណ៍ដោយលោកព្រះរាជអាជ្ញា និងប្តឹងឧទ្ធរណ៍ដោយឈ្មោះ **បភ** ជាដើមបណ្តឹងរដ្ឋប្បវេណី ទុកជាបានការដដែល។

៣- សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។ បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់។

- បានឃើញបណ្តឹងសាទុក្ខលេខ០៤ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០២ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ប្តឹងមិនសុខចិត្ត ពីសាលដីកាព្រហ្ម

ទណ្ឌលេខ០១ “គ” ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទី២ នៃសេចក្ដីសម្រេច។

- បានឃើញសារណា ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០២ របស់អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ (ម្ចាស់បណ្ដឹងសាទុក្ខ) ធ្វើឡើងក្នុងកំណត់ច្បាប់។

- បានឃើញសារណាតប ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៣ របស់ជនជាប់ចោទឈ្មោះ **ទស** (ជាចុងចោទសាទុក្ខ) ធ្វើឡើងក្នុងកំណត់ច្បាប់។

- បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា៖ រឿងនេះផ្អែកលើកត្តាសត្យានុម័តឃើញថា មានការគិតទុកជាមុនមនុស្សឃាតដោយចេតនា មានអ្នកជួលពិតប្រាកដ។ ដូច្នេះសូមធ្វើការចោទប្រកាន់ជនល្មើសទាំងអស់វិញទៅ ព្រះរាជអាជ្ញាអមតុលាការខេត្តកណ្ដាលដើម្បីចាត់ការតាមច្បាប់ព្រមទាំងទុកជាមោឃៈដីកាលើកលែងចោទប្រកាន់ទាំងអស់ និងរុករកអ្នកជួលសម្លាប់ក្នុងរឿងនេះឱ្យឃើញ។

- បានស្ដាប់ក្រឡាបញ្ជីអានសេចក្ដីសុំប្ដឹងសាទុក្ខ និង សារណារបស់ឯកឧត្ដមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ (ជាម្ចាស់បណ្ដឹងសាទុក្ខ) នៅពេលជំនុំជម្រះ។

- បានស្ដាប់ក្រឡាបញ្ជីអានសាវតាជាតិ និង សារណាតបរបស់ឈ្មោះ **ទស** (ជាចុងបណ្ដឹងសាទុក្ខ) នៅពេលជំនុំជម្រះ។

- បានស្ដាប់ចម្លើយអះអាងរបស់ឈ្មោះ **ផផ** (ជាចុងបណ្ដឹងសាទុក្ខ) នាពេលសវនាការថា៖ ខ្ញុំបាទមិនបានចូលរួមប្រព្រឹត្តិអំពើល្មើសទេ ហើយមិនដែលស្គាល់គ្រួសារជនរងគ្រោះដែរ ចម្លើយប៉ូលីសមានការបង្ខិតបង្ខំ។ ខ្ញុំបាទពុំ

ដឹងទេ ដឹងនៅពេលចាប់ ខ្ញុំបាទមកដល់ស្នងការ គេបង្ហាញរូបថតឱ្យខ្ញុំបាទមើល សូមតុលាការដោះលែង។

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ...ជាមេធាវីការពារជនជាប់ចោទឈ្មោះ **ផផ** (ជាចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជម្រះថាៈ តុលាការថ្នាក់ក្រោមដោះលែងជនល្មើសដទៃទៀត នៅសល់កូនក្តីខ្លួនតែម្នាក់ឯង ចម្លើយនៅប៉ូលីសមានការគំរាមកំហែងកូនក្តីខ្លួន ត្រូវបានលើកលែងចោទប្រកាន់ តែព្រះរាជអាជ្ញាប្តឹងឧទ្ធរណ៍ ការប្តឹងនេះគឺថ្លោះសិទ្ធិហើយ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក...ជាមេធាវីការពារជនជាប់ចោទឈ្មោះ **ទស** (ជាចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជម្រះថាៈ កូនក្តីរបស់ខ្លួនមិនបានចូលរួមប្រព្រឹត្តិបទល្មើសទេ នៅថ្ងៃកើតហេតុឈ្មោះ **ទស** នៅវត្តកៀនស្វាយ មានលោកតា **ទផ** ជាសាក្សីព្រមទាំងមានការបញ្ជាក់ពីមេឃុំទៀតផង។ សូមតម្កល់សាលដីកាសាលាឧទ្ធរណ៍សាទុក្ខជាបានការដដែល។

- បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការអមតុលាការកំពូលនៅពេលជំនុំជម្រះថា៖ រឿងនេះមុនពេលឪពុកស្លាប់ គាត់បានស្រែកប្រាប់កូនថាៈ អ្នកសម្លាប់គាត់គឺឈ្មោះ **ផផ**។ ម្យ៉ាងទៀតនៅប៉ូលីសជនជាប់ចោទឆ្លើយថា មានការគំរាមកំហែង តែមកដល់ចៅក្រមស៊ើបអង្កេតសរសេរចម្លើយ ហើយឱ្យខ្លួនឱ្យផ្តិតមេដៃនោះ គឺពុំគួរឱ្យជឿបានឡើយ សូមតម្កល់ការសន្និដ្ឋានខាងលើទុកនៅដដែល។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានស្តាប់បណ្តឹងសាទុក្ខ និង សារណារបស់ឯកឧត្តមអគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ចម្លើយរបស់ជនជាប់ចោទឈ្មោះ **ផផ** សារណារបស់ **ទស** សេចក្តីសន្និដ្ឋានរបស់មេធាវីរបស់ឈ្មោះ **ផផ** និងសេចក្តីសន្និដ្ឋានរបស់មេធាវីរបស់ឈ្មោះ **ទស**។

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការកំពូល**

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ០៤ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០២ របស់ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូល អាចលើករឿងនេះ មកជំនុំជម្រះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំនុំជម្រះក្តី។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេច តម្កល់ដីកាលើកលែងចោទប្រកាន់លេខ៧២ ដ.ក.ល.ច ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០០ និងដីកាលើកលែងចោទប្រកាន់លេខ១៧ ដ.ក.ល.ច ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០០ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តកណ្តាលនោះ គឺជាការភាន់ច្រឡំពីព្រោះថា៖

+ នៅចំពោះមុខនគរបាល ក៏ដូចជាចំពោះមុខចៅក្រមស៊ើបអង្កេតជនជាប់ចោទឈ្មោះ **ផផ** បានបញ្ជាក់ថា ខ្លួនជាអ្នកស្រែកហៅជនរងគ្រោះឱ្យចេញពីផ្ទះ ហើយអ្នកដែលបាញ់ជនរងគ្រោះគឺឈ្មោះ **អ** ឈ្មោះ **បរ** និងឈ្មោះ **ទស**។

+ ដីកាលើកលែងចោទប្រកាន់ឈ្មោះ **ទស** ឈ្មោះ **បរ** និងឈ្មោះ **ផផ** ពុំបានជូនដំណឹងទៅដើមបណ្តឹងរដ្ឋប្បវេណីទេ ដែលជាការរំលោភទៅលើមាត្រា

៩១នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ម្យ៉ាងទៀត ដីកាលើកលែងចោទប្រកាន់លើឈ្មោះ **បរ** និងលើឈ្មោះ **តស** ជាដីកាដាច់ដោយឡែកពីគ្នា ប៉ុន្តែចុះលេខ និងកាលបរិច្ឆេទដូចគ្នា។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍លើកយកតែបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៥ ខែតុលា ឆ្នាំ២០០១ របស់អ្នកស្រី **បភ** មកពិចារណាដោយពុំបានពិចារណាលើបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០១ របស់អ្នកស្រី **បភ** ផងនោះ គឺជាការភាន់ច្រឡំពីព្រោះថាៈ

+ បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០១ ដែលត្រូវបានមហាអយ្យការអមសាលាឧទ្ធរណ៍ ទទួលនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ ហើយបញ្ជូនទៅឱ្យតុលាការខេត្តកណ្តាល ដើម្បីចាត់ឱ្យក្រឡាបញ្ជីចុះបណ្តឹងឧទ្ធរណ៍នោះ អ្នកស្រី **បភ** បានប្តឹងពីដីកាលើកលែងចោទប្រកាន់លើឈ្មោះ **បរ** និងឈ្មោះ **ទស**។

+ បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ គឺក្រឡាបញ្ជីបានចុះបណ្តឹងឧទ្ធរណ៍ត្រង់ចំណុចតែលើកលែងចោទប្រកាន់លើឈ្មោះ **ទស** តែម្នាក់។

- យល់ឃើញថា ចម្លើយរបស់ជនជាប់ចោទនៅចំពោះមុខនគរបាល ក៏ដូចចំពោះមុខចៅក្រមស៊ើបអង្កេត បានបញ្ជាក់ថា មានជនផ្សេងទៀត បានជួលជនល្មើសទាំង៣នាក់ ឱ្យធ្វើឃាតជនរងគ្រោះ ប៉ុន្តែតំណាងអយ្យការអមតុលាការខេត្តកណ្តាល ពុំបានផ្តើមចោទប្រកាន់លើជនទាំងនោះឡើយ។

- យល់ឃើញ មានពិរុទ្ធគ្រប់គ្រាន់លើឈ្មោះ **ផផ** , **ទស** ,**បរ** និងជនផ្សេងទៀត ដែលបានជួលជនទាំង៣នាក់ឱ្យធ្វើឃាតលើឈ្មោះ **ភត** ពីបទៈ មនុស្សឃាតដោយចេតនានិងគ្រោងទុកជាមុន។

- យល់ឃើញ ការដែលលោកមេធាវីជនជាប់ចោទលើកឡើងថា ភស្តុតាងដាក់បន្ទុកលើកូនក្តីរបស់លោកធ្វើឡើងដោយមានការក្លែងបន្លំ ហើយកូនក្តីរបស់លោក ពុំបានចូលរួមក្នុងការប្រព្រឹត្តិបទល្មើសនេះទេ នោះពុំទាន់មានភស្តុតាងដោះបន្ទុកណាជួនល្មមគួរឱ្យតុលាការជឿបានឡើយ។

- យល់ឃើញ ជនជាប់ចោទឈ្មោះ **ទស** បានធ្វើសារណាការពាររឿងក្តីរបស់ខ្លួនជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមតាមការនោះទេ ដូច្នេះតុលាការកំពូលជំនុំជម្រះរឿងនេះកំបាំងមុខជនជាប់ចោទ **ទស** ប៉ុន្តែចាត់ទុកជាចំពោះមុខ។

- យល់ឃើញ សាលដីកាព្រហ្មទណ្ឌលេខ០១ "គ" ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចក្តីមកនេះមានការខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខជនជាប់ចោទឈ្មោះ **ផផ** កំបាំងមុខជនជាប់ចោទឈ្មោះ **ទស** ប៉ុន្តែចាត់ទុកជាចំពោះមុខៈ

១- ទទួលបណ្តឹងសាទុក្ខលេខ០៤ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០២ របស់ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ទុកជាត្រឹមត្រូវតាមទម្រង់នឹងគតិច្បាប់។

២- ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ០១ "គ" ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ទាំងមូល។

៣- បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ៣៩ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០២ របស់តុលាការកំពូលទៅអយ្យការអមតុលាការខេត្តកណ្តាល ដើម្បី

អនុវត្តតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលេខ៣១១ ចុះថ្ងៃទី៤ ខែតុលា ឆ្នាំ១៩៩៩ និងធ្វើការផ្ដើមចោទប្រកាន់លើឈ្មោះ **បរ** និងអ្នកជួលសម្លាប់ជនរងគ្រោះ។

៤- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៣។